ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២០/១៩ - ធីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ ឈឺវ ភិរម្យ
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី**
អាសយដ្ឋាន ៖ ផ្លូវ៣៧១ ភូមិម័រ សង្កាត់ដង្កោខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៧ ៦៨៥ ៨២២ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោកស្រី ជាវ គន្ធា | ប្រធានរដ្ឋបាល |
| ២- លោកស្រី កែម ខេងលី | រដ្ឋបាល |
| ៣- កញ្ញា ញ៉ឹម ណារី | រដ្ឋបាល |
| ៤- លោក អ៊ុំ វិសាល | មន្ត្រីច្បាប់GAMC |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី**
អាសយដ្ឋាន ៖ ផ្លូវ៣៧១ ភូមិម័រ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៧០ ៣៤៥ ៧៥២/០៨៩ ៧៤៤ ៦៣៧ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក មុំ សុភ័ស្ត | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ២- លោក មៀច សុជា | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ៣- លោកស្រី ប៉ា លក្ខិណា | ប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំរោងចក្រ |

| | |
|---|---|
| ៤- លោក ភឿន គី | អនុប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំរោងចក្រ |
| ៥- លោកស្រី អ៊ឹម ដឿប | លេខាសហជីពស្មារតីកម្មករខ្មែរប្រចាំរោងចក្រ |
| ៦- លោក ភឿន វ៉ាន់នី | ហិរញ្ញិក |
| ៧- កញ្ញា ស៊ីប លីនដា | ពេទ្យ |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាំងអស់នៅតែទាមទារឲ្យក្រុមហ៊ុនរក្សាទុកពេទ្យឈ្មោះ ស៊ីប លីនដា អត្តលេខ ១៩៦៩ ឲ្យនៅធ្វើការងារជាធម្មតាវិញ ព្រោះគាត់យកចិត្តទុកដាក់ជាមួយកម្មករនិយោជិតពេលមានជំងឺ និងគាត់គ្មានកំហុសធ្ងន់ធ្ងរឡើយ។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកឈ្មោះ ស៊ីប លីនដា ចូលធ្វើការងារវិញបានទេ ព្រោះគាត់បានធ្វើខុសនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន តែក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនគាត់តាមច្បាប់ស្តីពីការងារ។

២- កម្មករនិយោជិតនៅតែទាមទារឲ្យក្រុមហ៊ុនអនុវត្តតាមប្រកាសលេខ ៤៤៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា មុនឆ្នាំ២០១៩ ចំពោះកម្មករនិយោជិតមានកិច្ចសន្យាមានថិរវេលាមិនកំណត់ ក្រុមហ៊ុនបានបង់ប្រាក់បំណាច់អតីតភាព ៥% ជារៀងរាល់ឆ្នាំរួចហើយ។ ដូច្នេះ ក្រុមហ៊ុននឹងបន្តបើកជូន៧.៥ ថ្ងៃ រៀងរាល់ខែមិថុនា និងខែធ្នូ ចាប់ពីឆ្នាំ២០១៩ នេះតទៅ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) លេខ ១៥០ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ៧កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ នៃក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ស្តីពីការស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារ ចំនួន ៤ ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក និងផ្អែកតាមលិខិតបង្គាប់ការរបស់ឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩ នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញ ធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សា នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នា ចំនួន ២ ចំណុច លើការទាមទារចំនួន ៤ ចំណុច។ ចំណុចមិនសះជាចំនួន ២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) លេខ ១៩០ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៤ ខែមីនា ឆ្នាំ ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ២ ចំណុចនេះ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៩ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ១ ចំណុច ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាលើចំណុចវិវាទទី២។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនឹងពិចារណាចំណុចវិវាទដែលមិនសះជាដែលនៅសល់ ចំនួន ១ ចំណុច គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ទៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់លោក YOSHIDA TOKIHIKO ជានាយកក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ចុះថ្ងៃសៅរ៍ ១១រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី០២ ខែមីនា ឆ្នាំ

THE ARBITRATION COUNCIL

២០១៩ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល សូមផ្ទេរសិទ្ធិជូន លោកស្រី ធារ៉ា គន្ធា លោកស្រី កែម ខេងលី និងកញ្ញា ញ៉ឹម ណារី និងលោក អ៊ុំ វិសាល។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី លេខ MOC ៥៣៩៥២៤០៩ ពណ ចបព ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១។

៣- លក្ខន្តិកៈក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) បានតម្កល់ទុកលេខ ០០០០៦០១៦ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ចុះទិដ្ឋាការលេខ ០០៥ កប/អក/អធក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ និងបានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ ដោយនាយកដ្ឋានអធិការកិច្ចការងារ។

៥- កិច្ចសន្យាសាកល្បងការងាររបស់ឈ្មោះ ចាន់ ស្រីនាង ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២។

៦- កិច្ចសន្យាការងារមានថិរវេលាកំណត់ របស់ ចាន់ ស្រីនាង ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២។

៧- កិច្ចសន្យាការងារមានថិរវេលាកំណត់ របស់ ចាន់ ស្រីនាង ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

៩- កំណត់ហេតុសួរព័ត៌មានតំណាងនិយោជក ក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ចុះថ្ងៃព្រហស្បតិ៍ ២ រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

១០-កំណត់ហេតុស្តីពីកិច្ចប្រជុំក្លឹបធនធានមនុស្សផ្នែកវិស័យកាត់ដេរ និងស្បែកជើងនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។

១១- លិខិតកំណត់ត្រាព្រមព្រៀង ចុះថ្ងៃសៅរ៍ ៧កើត ខែបុស្ស ឆ្នាំច ពស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩។

១២- លិខិតជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាការងារកញ្ញា ស៊ុប លីនដា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

១៣- លិខិតរបស់សហគ្រាស ធីនើ ហ្វេសិន (ខេមបូឌា) ជម្រាបមក កញ្ញា ស៊ុប លីនដា ស្តីពីការរំលាយកិច្ចសន្យាការងារ របស់កញ្ញា ស៊ុប លីនដា ចុះថ្ងៃសៅរ៍ ៤កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក សព ២៥៦២ ត្រូវនឹងថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩។

១៤- តារាងនៃការទូទាត់ប្រាក់ចំពោះកម្មករដែលឈប់ និងចុងសន្លឹកបើកប្រាក់ខែរបស់កញ្ញា ស៊ុប លីនដា។

១៥- ប្រាក់បំណាច់ឆ្នាំ និងប្រាក់ ៥ % សម្រាប់ខែសីហា ឆ្នាំ២០១៥។

១៦- ប្រាក់បំណាច់ឆ្នាំ និងប្រាក់ ៥ % សម្រាប់ខែសីហា ឆ្នាំ២០១៦។

១៧- ប្រាក់បំណាច់ឆ្នាំ និងប្រាក់ ៥ % សម្រាប់ខែសីហា ឆ្នាំ២០១៧។

THE ARBITRATION COUNCIL

១៨- ប្រាក់បំណាច់ឆ្នាំ និងប្រាក់ ៥ % សម្រាប់ខែសីហា ឆ្នាំ២០១៨។

១៩- ប្រាក់បំណាច់អតីតភាព ៥% សម្រាប់ខែមករា ឆ្នាំ២០១៩ បើកផ្តាច់ទាំងអស់សម្រាប់ឆ្នាំ ២០១៨។

២០- ឯកសាររបស់ក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ចុះថ្ងៃអង្គារ ៧កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពី សារណាការពារ។

២១- លិខិតស្នើសុំបដិសេធរបស់ប្រតិភូបុគ្គលិក។

២២- លិខិតចាត់តាំងប្រតិភូចរចា ដោះស្រាយការងាររួមនៅក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ចុះថ្ងៃសៅ ៩រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ ២០១៩។

២៣- ស្នាមមេដៃកម្មករនិយោជិតនៃក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ស្នើសុំបដិសេធលើឯកសារ ទាមទារលក្ខខណ្ឌការងារចំណុចទី២។

២៤- លិខិតព្រមានឈ្មោះ ស៊ុប លីនដា ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨។

២៥- លិខិតព្រមានឈ្មោះ ស៊ុប លីនដា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

២៦- លិខិតចេញចូលបន្ទប់ពេទ្យ។

២៧- ប្រាក់បំណាច់ឆ្នាំ និងប្រាក់ ៥ % សម្រាប់ខែសីហា ឆ្នាំ២០១៧។

២៨- ប្រាក់បំណាច់អតីតភាព ៥% សម្រាប់ខែមករា ឆ្នាំ២០១៩ បើកផ្តាច់ទាំងអស់សម្រាប់ឆ្នាំ ២០១៨។

២៩- ប្រាក់បំណាច់ឆ្នាំ និងប្រាក់ ៥ % សម្រាប់ខែសីហា ឆ្នាំ២០១៨។

៣០- កិច្ចសន្យាការងារមានថិរវេលាកំណត់ របស់ ស៊ុប លីនដា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧។

៣១- កិច្ចសន្យាការងារមានថិរវេលាកំណត់ របស់ ស៊ុប លីនដា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦។

៣២- ឯកសារភាសាបរទេស។

៣៣- ឯករូបភាព។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី លេខ ៦៨៧ ក.ប/វបវក ចុះថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧។

២- លិខិតលេខ ៣៣០ ក.ប/វក ចុះថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រកាសថា សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន (ខេមបូឌា) ខូអិលធីឌី ជាអង្គការវិជ្ជាជីវៈមួយ បានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់។

៣- កំណត់ហេតុនៃផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

៤- លិខិតអញ្ជើញលេខ ១១៨ កប/អក/វក របស់នាយកដ្ឋានវិវាទការងារ អញ្ជើញលោកស្រី ប៉ា លក្ខិណា, លោក ភឿន គី, លោកស្រី អ៊ឹម ជៀប និងលោក ភឿន វ៉ាន់នី ដើម្បីចូលរួមផ្តល់ព័ត៌មាន ចុះថ្ងៃចន្ទ ៧កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩។

៥- លិខិតអញ្ជើញលេខ ១៥៦ កប/អក/វក របស់នាយកដ្ឋានវិវាទការងារ អញ្ជើញលោកស្រី ប៉ា លក្ខិណា, លោក ភឿន គី, លោកស្រី អ៊ឹម ជៀប និងលោក ភឿន វ៉ាន់នី ដើម្បីចូលរួមផ្សះផ្សា ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩។

៦- កំណត់ហេតុសួរព័ត៌មានតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃពុធ ៩កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩។

៧- លិខិតលេខ ០០៩/១៩ ស.ស.ស.ក.ខ ចុះថ្ងៃសុក្រ ១២រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាខាសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីស្នើសុំដោះស្រាយ សម្របសម្រួល លក្ខខណ្ឌការងារ ៤ ចំណុច។

៨- លិខិតលេខ ០០២/១៩ ស.ស.ស.ក.ខ ចុះថ្ងៃអង្គារ ៩រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ របស់សាខាសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី គោរពជូន លោកនាយកក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ស្តីពីសំណើសុំជួបពិភាក្សាដោះស្រាយ លក្ខខណ្ឌការងារ ៤ ចំណុច។

៩- លិខិតចាត់តាំងប្រតិភូចរចា ដោះស្រាយការងាររួមនៅក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ចុះថ្ងៃសៅរ៍ ៥រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩។

១០-ស្នាមមេដៃកម្មករនិយោជិតក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) គាំទ្រប្រតិភូចរចាដើម្បីមានសិទ្ធិដោះស្រាយលក្ខខណ្ឌការងារ ៤ ចំណុច។

១១- ឯកសារគណនីបញ្ជើសំចៃ។

១២- លិខិតជំទស់របស់តំណាងប្រតិភូចរចា ចុះថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការប្តឹងជំទាស់លើការផ្តល់ឯកសារបន្ថែមរបស់ក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។

១៣- ឯកសារភាសាបរទេស។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី លេខ ១៩០ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ខូអិលធីឌី លេខ ០០៤/១៩ កប/អក/លបវ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៩ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៤២ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៣ រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៤៣ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៣រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ និងបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ក្រោមលេខចុះបញ្ជីថ្មី ០០០០៦០១៦ (លេខចុះបញ្ជីចាស់ Inv. ១៧០៤E/២០១១) ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១។ យោងតាមការលើកឡើងរបស់និយោជក នៅថ្ងៃសវនាការ បច្ចុប្បន្នក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតប្រមាណជា ៤៧០ នាក់។
- សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខចុះបញ្ជី ១១២១៧០២៨៤ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ និងមានលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីព លេខ ៣៣០ ក.ប/វក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ដោយមានឈ្មោះ លោកស្រី ប៉ា លក្ខិណា ជាប្រធានសហជីព, លោក គឿន គី ជាអនុប្រធាន និង លោកស្រី អ៊ឹម ជៀប ជាលេខាធិការិនី។
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៤/១៩ កប/អក/លបវ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ ដូចជា ៖ ប៉ា លក្ខិណា, អ៊ឹម ជៀប, និង គឿន វ៉ាន់នី ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ជីនើ ហ្វេសិន (ខេមបូឌា) ក្នុងការដោះស្រាយវិវាទការងាររួម។
- នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិតទាំង ៣ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ ព្រមទាំងកម្មករនិយោជិតឈ្មោះ ស៊ីប លីនដា និង គឿន គី។

- មិនមានអង្គហេតុណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកក្សាទុកពេទ្យឈ្មោះ ស៊ីប លីនដា អត្តលេខ ១៩៦៩ ឱ្យនៅធ្វើការងារជាធម្មតាវិញ ព្រោះគាត់យកចិត្តទុកដាក់ជាមួយកម្មករនិយោជិតពេលមានជំងឺ និងគាត់គ្មានកំហុសធ្ងន់ឡើយ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកទទួលយកកម្មករនិយោជិតឈ្មោះ ស៊ីប លីនដា តួនាទីជាគិលានុបដ្ឋាកយិកា ឱ្យចូលធ្វើការងារវិញ។
- ភាគីទាំងពីរបានទទួលស្គាល់ថា ៖
  - កម្មករនិយោជិត ស៊ីប លីនដា បានចូលធ្វើការដំបូងនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ដោយមានកិច្ចសន្យាការងារសាកល្បង ចំនួន ២ខែ បន្ទាប់មកបានចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ចំនួន ១០ ខែ និងក្រោយមកទៀត គាត់បានបន្តចុះកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលា ចំនួន ១ ឆ្នាំ បន្តទៀត ដែលត្រូវផុតលត់នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨។ និយោជកបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ចំនួន ៥ ភាគរយ នៅពេលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវដល់ការកំណត់ (ទូទាត់រៀងរាល់មួយឆ្នាំម្តង)។
  - បន្ទាប់ពីគាត់ធ្វើការបានពីរឆ្នាំរួចមក និយោជកលែងចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាជាមួយកម្មករនិយោជិត ស៊ីប លីនដា ទៀតហើយ គឺនិយោជកបានបន្តប្រើកិច្ចសន្យាការងារមានថិរវេលាមិនកំណត់តែម្តង ចាប់ពីខែសីហា ឆ្នាំ២០១៨ មក។
  - និយោជកបានបញ្ឈប់កម្មករនិយោជិតពីការងារនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយមានចេញជាលិខិតបញ្ឈប់ផងដែរ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖
  - មានកម្មករនិយោជិត ចំនួន ២២៣ នាក់ បានផ្តិតមេដៃស្នើសុំទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ស៊ីប លីនដា ឱ្យចូលធ្វើការងារវិញ។
  - កម្មករនិយោជិត ស៊ីប លីនដា គឺមិនបានប្រព្រឹត្តកំហុសធ្ងន់នោះទេ។ គាត់គឺមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ហេតុនេះ និយោជកបានបញ្ឈប់គាត់មិនត្រឹមត្រូវតាមនីតិវិធីទេ ដោយមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរ មុនពេលបញ្ឈប់ ជាក់ស្តែង និយោជកបានប្រាប់គាត់ផ្ទាល់មាត់ថាបញ្ឈប់នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ ថានឹងបញ្ឈប់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ ប៉ុន្តែក្រោយមក បែជាបញ្ឈប់គាត់នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៩ វិញ។
- នៅថ្ងៃសវនាការភាគីនិយោជកបានជំទាស់នឹងយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយលើកឡើងថា ករណីបញ្ឈប់កម្មករនិយោជិត ស៊ីប លីនដា គឺជាវិវាទបុគ្គល មិនមែនជាវិវាទការងាររួមនោះទេ ដោយមូលហេតុថា កម្មករនិយោជិតដែលបានផ្តិតមេដៃទាមទារនៅក្នុងសំណុំរឿងនេះគឺមិនបានទាមទារត្រង់ចំណុចនេះទេ។ ជាងនេះទៀត កម្មករនិយោជិតទាំងនោះ បានផ្តិតមេដៃដកការទាមទាររបស់គាត់វិញផងដែរ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចទទួលយកកម្មករនិយោជិត ស៊ីប លីនដា ឱ្យចូលធ្វើការវិញបានទេ ដោយមូលហេតុថា ៖

THE ARBITRATION COUNCIL

- ◦ និយោជកបានជូនដំណឹងមុនជាលាយលក្ខណ៍អក្សរពីការបញ្ឈប់កម្មករនិយោជិត ស៊ីប លីនដា នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។
- ◦ ការបញ្ឈប់នេះ គឺផ្អែកលើមូលហេតុថា កម្មករនិយោជិត ស៊ីប លីនដា បានធ្វើខុសនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនត្រង់ប្រការ ១០ ដោយបានប្រព្រឹត្តកំហុសស្រាលដដែលៗចំនួន ៣ដង ហេតុនេះ និយោជកមានសិទ្ធិក្នុងការបញ្ចប់កិច្ចសន្យាការងារគាត់។
- ◦ កំហុសដដែលៗ ៣ដងនោះ មានដូចជា៖ កំហុសទី១.នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ គាត់មិនបានបំពេញរបាយការណ៍ពេទ្យបានត្រឹមត្រូវ ដោយមិនមានព័ត៌មានច្បាស់លាស់អំពីម៉ោងចូល និងម៉ោងចេញពីគិលានដ្ឋានរបស់កម្មករនិយោជិត និងមិនមានការវិនិច្ឆ័យអំពីអាការៈជំងឺរបស់កម្មករនិយោជិត នៅពេលដែលគាត់ចូលសម្រាកព្យាបាលនៅគិលានដ្ឋានរបស់ក្រុមហ៊ុន។ ចំពោះកំហុសទី១នេះ និយោជកបានហៅគាត់ ដោយណែនាំគាត់ និងព្រមានផ្ទាល់មាត់ដល់គាត់ម្តងហើយ។ កំហុសទី២. នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ គាត់នៅតែបំពេញរបាយការណ៍ពេទ្យមិនច្បាស់លាស់ដដែល ហើយបានឲកម្មករនិយោជិតយកក្រេម និងម្សៅទៅលាបនៅបន្ទប់ពេទ្យទៀតផង។ ករណីនេះ និយោជកចេញលិខិតព្រមានជាលើកទី២ ជាលាយលក្ខណ៍អក្សរ ប៉ុន្តែគាត់មិនព្រមផ្តិតមេដៃ។ កំហុសទី៣ គឺនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ គឺគាត់នៅតែមានកំហុសដដែល និងអនុញ្ញាតឲកម្មករនិយោជិតដាក់ខោអាវនៅលើគ្រែអ្នកជំងឺ ដោយមិនមានសណ្តាប់ធ្នាប់។ និយោជកបានព្រមានគាត់ និងចេញជាលិខិតជូនដំណឹងបញ្ឈប់គាត់ ប៉ុន្តែគាត់នៅតែមិនព្រមផ្តិតមេដៃ។
- ◦ និយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនគាត់ ដែលមានដូចជា ៖ ប្រាក់ឈ្នួលចុងក្រោយ, ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ និងប្រាក់បំណាច់អតីតភាពការងារ ចំនួន ៧.៥ថ្ងៃ (ប្រាំពីរថ្ងៃកន្លះ) ដោយមូលហេតុថា កិច្ចសន្យាការងារមានថិរវេលាមិនកំណត់របស់គាត់ គឺមានថិរវេលាមិនលើសពី ៦ខែ នោះទេ ព្រោះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់គាត់ដែលមានថិរវេលា ២ឆ្នាំនោះ គឺត្រូវបាននិយោជកផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ចំនួន ៥ ភាគរយ រួចហើយ។

- ភាគីកម្មករនិយោជិតបានលើកឡើងថា នៅគិលានដ្ឋានក្រុមហ៊ុន គឺមានកម្មករនិយោជិតចេញចូលច្រើន ខ្លះមកបើកថ្នាំ ខ្លះសម្រាក ខ្លះទៀតមកកោសខ្យល់ជាដើម។ ហេតុនេះ គាត់មិនអាចកត់ព័ត៌មានបានគ្រប់ពេលនោះទេ។ ចំណែកឯ ក្រេមម្សៅវិញ គាត់ក៏មិនដឹងថាមានកម្មករនិយោជិតយកចូលទៅក្នុងគិលានដ្ឋាននោះដែរ។ ចំពោះកំហុសលើកទី១ គឺនិយោជកបានប្រាប់ និងណែនាំដោយផ្ទាល់មាត់ ចំណែកកំហុសលើកទី២ និងទី៣ គឺនិយោជកមិនបានចេញជាលិខិតព្រមានអ្វីនោះទេ ហើយក៏មិនបានហៅកម្មករនិយោជិតទៅព្រមានដែរ។
- នៅថ្ងៃដាក់ឯកសារ ភាគីកម្មករនិយោជិតបានដាក់ស្នាមមេដៃកម្មករនិយោជិតគាំទ្រ[illegible] ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩ ដែលមានស្នាមមេដៃកម្មករនិយោជិតសរុប ចំនួន ២២៣ នាក់ ដើម្បីទាមទារលក្ខខណ្ឌការងារ ចំនួន ៤ ចំណុច ក្នុងនោះគឺមានទាមទារឲនិយោជកទទួលយកកម្មករនិយោជិត ស៊ីប លីនដា ចូលធ្វើការវិញដែរ។

- នៅថ្ងៃដាក់ឯកសារ ភាគីនិយោជកបានដាក់លិខិតស្នើសុំបដិសេធរបស់កម្មករនិយោជិតលើឯកសារទាមទារលក្ខខណ្ឌការងារចំណុចវិវាទទី២ (ពាក់ព័ន្ធនឹងកម្មករនិយោជិត ស៊ីប លីនដា) ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ក្នុងនោះ គឺមានស្នាមមេដៃកម្មករនិយោជិតបដិសេធសរុប ចំនួន ២៣២ នាក់។
- នៅថ្ងៃជំទាស់ឯកសារ ភាគីកម្មករនិយោជិតបានដាក់លិខិតជំទាស់នឹងស្នាមមេដៃកម្មករនិយោជិតដែលដាក់ដោយភាគីនិយោជក ដោយលើកឡើងថា *"ស្នាមមេដៃជំទាស់របស់កម្មករនិយោជិត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ដែលភាគីក្រុមហ៊ុនបានរៀបចំឡើង គឺមិនបានបញ្ជាក់ប្រាប់កម្មករអោយបានច្បាស់លាស់ពីមូលហេតុនៃការផ្តិតមេដៃនេះឡើយ។...។"*

**ហេតុផលនៃសេចក្តីសម្រេច ៖**

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាអំពីភាគីដើមបណ្តឹងជាមុនសិន ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។"* ។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឲកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង និងលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី )*

យោងតាមអង្គហេតុបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតនោះទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"* ។

លើសពីនេះ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម។"*

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឲ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឲ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ (*សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល លេខ ២២៣/១៦-យូនីកតា ថេកណាឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបរើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និងលេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច*)។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងសំណុំរឿងនេះ នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៤/១៩ កប/អក/លបវ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ ដូចជា ៖ ប៉ា លក្ខិណា, អ៊ឹម ជៀប, និង គឿន វ៉ាន់ឌី ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ក្នុងការដោះស្រាយវិវាទការងាររួម។ នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិតទាំង ៣ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតទាំង ៣ នាក់ ខាងលើ គឺមានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាចំណុចវិវាទនៅក្នុងសំណុំរឿងនេះ សម្រាប់កម្មករនិយោ-ជិត នៅក្នុងក្រុមហ៊ុន ធីនើ ហ្វេសិន (ខេមបូឌា) ដែលជាដើមបណ្ដឹង។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឲ្យនិយោជកទទួលយកកម្មករនិយោជិតឈ្មោះ ស៊ីប លីនដា មានតួនាទីជាគិលានុបដ្ឋាកយិកា ឲ្យចូលធ្វើការងារវិញ**

នៅថ្ងៃសវនាការភាគីនិយោជកបានលើកឡើងថា វិវាទនេះគឺជាវិវាទបុគ្គល មិនមែនជាវិវាទការងាររួមទេ។

ហេតុនេះ មុននឹងពិចារណាការទាមទារក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានយុត្តាធិការលើវិវាទនេះ ដែរ ឬទេ?

ប្រការ ៣២ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញា-កណ្ដាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្ដាលត្រូវសម្រេចសេចក្ដីលើវិវាទការងាររួម ដែលដាក់មកខ្លួន ដោយយោងទៅតាមមាត្រា ៣០៩ នៃច្បាប់ស្ដីពីការងារ។"*

តាមរយៈប្រការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានយុត្តាធិការដោះស្រាយតែវិវាទការងាររួមប៉ុណ្ណោះ។

ជាគោលការណ៍ អធិការកិច្ចការងារ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានភារកិច្ចក្នុងការសម្រេចថា តើវិវាទណាមួយជាវិវាទបុគ្គល ឬវិវាទការងាររួម មុនពេលបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញា-កណ្ដាល។ ដូច្នេះ ជាធម្មតា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងគោរពតាមការសម្រេចរបស់អធិការកិច្ចការងារ និង

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រសិនបើគ្មានហេតុផលជំទាស់ច្បាស់លាស់នោះទេ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលនៃចំណុចវិវាទទី៤, លេខ ៤១/០៤-មីកាសា, លេខ ០៧/០៥-កូកា កូឡា ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ៤៥/០៧-វីលសិន ហេតុផលនៃចំណុចវិវាទទី៤, លេខ ១៣/០៨- តេអ៉ាតិច្ស ហេតុផលនៃចំណុចវិវាទទី២, លេខ ១៤/១១-ជី អេច ជី ហេតុផលនៃចំណុចវិវាទទី២ និងលេខ ២៥៣/១៤- តូតាល់ កម្ពុជា* )។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៥/០៧-វីល សិន ហេតុផលចំណុចវិវាទទី៤ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសន្មតថា “*រាល់ការទាមទារទាំងអស់នៅក្នុងរបាយការណ៍មិនសះជារបស់ក្រសួងការងារ គឺជាវិវាទរួម។ ដោយសារតែភាគីនិយោជកបានធ្វើការជំទាស់ទៅលើការសន្មតនេះ និយោជកមានបន្ទុកផ្តល់ភស្តុតាងបញ្ជាក់អំពីអំណះអំណាងរបស់ខ្លួន*”។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្មតថា រាល់ការទាមទារទាំងអស់នៅក្នុងរបាយការណ៍មិនសះជារបស់ក្រសួងការងារ គឺជាវិវាទការងាររួម។ យ៉ាងណាមិញ ក្នុងករណីដែលនិយោជកធ្វើការជំទាស់ថា វិវាទដែលមានក្នុងរបាយការណ៍មិនសះជារបស់ក្រសួងការងារ គឺមិនមែនជាវិវាទរួមនោះ ភាគីនិយោជកត្រូវមានបន្ទុកភស្តុតាង ដើម្បីបញ្ជាក់ពីអំណះអំណាងរបស់ខ្លួន ដោយសារតែភាគីនិយោជកបានធ្វើការជំទាស់ទៅលើការសន្មតនេះ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿង*លេខ ៤៥/០៧-វីល សិន ហេតុផលនៃចំណុចវិវាទទី៤ និងលេខ ១៣/០៨-តេអ៉ាតិច្ស ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនដែរ។

ក្នុងសំណុំរឿងនេះ ភាគីនិយោជកបានលើកឡើងថា ចំណុចវិវាទនេះ មិនមែនជាវិវាទការងាររួមទេ ដោយមូលហេតុថា វាជាករណី បញ្ឈប់កម្មករនិយោជិត ស៊ីប លីនដា តែម្នាក់ប៉ុណ្ណោះ ហើយក៏មិនមានកម្មករនិយោជិតដទៃទៀតគាំគាំទ្រទាមទារចំណុចនេះដែរ។ មានន័យថា ត្រង់ចំណុចនេះ គឺមានស្នាមមេដៃកម្មករនិយោជិតដែលបានបញ្ជាក់ និងបដិសេធថា ពួកគាត់មិនបានទាមទារចំណុចវិវាទនេះទេ។

មាត្រា ៣០២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ “*វិវាទការងាររួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ នឹងបុគ្គលិករបស់ខ្លួនមួយចំនួន អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឲអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករ និយោជិត ហើយការវិវាទនេះអាចបណ្តាលឲសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឲខូចសន្តភាពសង្គម។*”

នៅក្នុងសំណុំរឿងលេខ ១០/០៣-ហ្សាក់ស៊ីនតិច ក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ជាក់ថា ៖ “*ដើម្បីអាចនិយាយបានថា វិវាទមួយ ជាវិវាទរួម ត្រូវបំពេញជាចាំបាច់តាមលក្ខខណ្ឌបីយ៉ាងនៃវិវាទការងាររួម ដូចមានចែងក្នុងច្បាប់ស្តីពីការងារ មាត្រា ៣០២។ លក្ខខណ្ឌបីយ៉ាងនោះគឺ ៖*

*ក- ជាវិវាទរវាងកម្មករមួយចំនួន និងនិយោជកម្នាក់ ឬច្រើននាក់*

*ខ- បញ្ហានៃវិវាទទាក់ទងនឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិ ដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ទទួលស្គាល់អង្គការវិជ្ជាជីវៈ ឬបញ្ហានៃទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត*

*គ- វិវាទនេះ អាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម*”។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើលក្ខខណ្ឌទាំងបីនៃវិវាទការងាររួមខាងលើនេះត្រូវបានបំពេញដែរ ឬទេ?

នៅក្នុងករណីនេះ យោងតាមអង្គហេតុ និងការពិនិត្យមើលលើឯកសារស្នាមមេដៃបណ្តឹងទាមទាររបស់ភាគីកម្មករនិយោជិតដែលមាន ចំនួនសរុប ២២៣ នាក់ និងស្នាមមេដៃបដិសេធរបស់កម្មករនិយោជិតសរុបចំនួន ២៣២ នាក់ ដែលដាក់ដោយភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតដែលមានស្នាមមេដៃទាមទារនៅក្នុងបណ្តឹងដើមរបស់ភាគីកម្មករនិយោជិត គឺបដិសេធមិនបានទាមទារចំណុចវិវាទពាក់ព័ន្ធនឹងកម្មករនិយោជិត ស៊ីប លីនដា នោះទេ។ ហេតុនេះ កម្មករនិយោជិត ទាំង ២៣២ នាក់នេះ គឺមិនមែនជាដើមបណ្តឹងនៅក្នុងចំណុចវិវាទនេះទេ។ យ៉ាងណាមិញ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា គឺមានវត្តមានរបស់កម្មករនិយោជិត ចំនួន ៥ នាក់ គឺមានឈ្មោះ ប៉ា លិក្ខិណា, គឿន ភី, អ៊ឹម ដៀប, គឿន វ៉ាន់ឌី និង ស៊ីប លីនដា ហើយកម្មករនិយោជិតទាំង ៥ នាក់នេះ គឺមិនមានឈ្មោះនៅក្នុងលិខិតជំទាស់របស់ភាគីនិយោជក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ខាងលើនេះទេ។ ហេតុនេះ ក្នុងករណីនេះ វិវាទនេះគឺកើតឡើងរវាងកម្មករនិយោជិត ចំនួន ៥ នាក់ និងនិយោជក។ សរុបមក លក្ខខណ្ឌទី “ក” ត្រូវបានបំពេញ។

ភាគីកម្មករនិយោជិតទាមទារឲនិយោជកទទួលយកកម្មករនិយោជិត ស៊ីប លីនដា ឲចូលធ្វើការវិញ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារក្នុងចំណុចនេះ ទាក់ទងលក្ខខណ្ឌការងារ ពោលគឺទាក់ទងនឹងកិច្ចសន្យាការងាររបស់កម្មករនិយោជិត។ ដូចនេះ លក្ខខណ្ឌ “ខ” ត្រូវបានបំពេញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាបន្តលើលក្ខខណ្ឌ-គ ថា តើវាត្រូវបានបំពេញដែរ ឬទេ? ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិត ស៊ីប លីនដា មានតួនាទីជាគិលានដុប្បដ្ឋាយិកានៅក្នុងក្រុមហ៊ុន ករណីនេះ គឺមានកម្មករនិយោជិតតែ ៤ នាក់ប៉ុណ្ណោះ ដែលគាំទ្រលើការទាមទារឲនិយោជកទទួលយកគាត់ (ស៊ីប លីនដា) ចូលធ្វើការវិញ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មកដល់ថ្ងៃសវនាការ ភាគីកម្មករនិយោជិតមិនបានលើកឡើងនូវចំណុចណាមួយ ដែលអាចឲក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការសន្និដ្ឋានបានថា វិវាទការងារនេះ នឹងអាចបង្កភាពរាំងស្ទះដល់សង្វាក់ផលិតកម្ម ឬអាចមានលទ្ធភាពបណ្តាលឲក្រុមហ៊ុនប្រព្រឹត្តទៅដោយពុំបានស្រួលនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះពុំបានបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គមនោះទេ ដូចនេះ លក្ខខណ្ឌ “គ” មិនត្រូវបានបំពេញឡើយ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីលក្ខខណ្ឌ “ក” និងលក្ខខណ្ឌ “ខ”ត្រូវបានបំពេញ ប៉ុន្តែលក្ខខណ្ឌ “គ” មិនត្រូវបានបំពេញនោះទេ។ ដោយសារលក្ខខណ្ឌមួយ ក្នុងចំណោមលក្ខខណ្ឌទាំងបីមិនត្រូវបានបំពេញ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទនេះ មិនមែនជាវិវាទការងាររួមទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការក្នុងការសម្រេចសេចក្តីលើសំណុំរឿងនេះឡើយ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឲនិយោជកទទួលយកកម្មករនិយោជិតឈ្មោះ ស៊ីប លីនដា មានតួនាទីជាគិលានដុប្បដ្ឋាយិកា ឲចូលធ្វើការងារវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

# សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឲនិយោជកទទួលយកកម្មករនិយោជិ ឈ្មោះ ស៊ុប លីនដា មានតួនាទីជាគិលានដុប្បដ្ឋាកយិកា ឲចូលធ្វើការងារវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ឈឹម តិរម្យ**

ហត្ថលេខា ៖ ---------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖---------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនណា**

ហត្ថលេខា ៖ ---------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL